5	R5- Access Road Line 5 (from Coffer dam to Intake)	0.7
6	R6- Access Road Line 6 (from R3 to Adit no.2)	0.78
	Total	30

ប្រភព: *គំនូរបច្ចេកទេស នៃ របាយការណ៍បច្ចុប្បន្នភាពសមិទ្ធិលទ្ធភាព ឆ្នាំ២០១៧*

៤.៦.៤ អាងស្តុកទឹក ទំនប់ និងប្រព័ន្ធសំណង់សិល្ប:ការ(ការងារទឹក)របស់វា
(Reservoir, Dams and Associated Hydraulic Structure)

៤.៦.៤.១ អាងស្តុកទឹក (Reservoir)

ជាគោលការណ៍នៃសំណង់វារីអគ្គិសនីនេះគឺ ធ្វើអាងស្តុកទឹក១កន្លែង ៖ ទំនប់ គឺទប់កាត់ស្ទឹងពោធិ៍សាត់នៅចំណុចអន្លង់ធ្ម៉ម ដែលនឹងបង្កើតជាអាង។ អាងនេះមានចំណុះស្តុកធម្មតា ១.២២៦,៥ លានម^3 មានផ្ទៃលើ (នៅនីវ៉ូ ១៨០ម) ទំហំ ៨.៥៩១ ហ.ត កំពស់ទឹកឡើងចុះធម្មតាគឺ ២០ម។ ***សម្គាល់:*** *ចំណុះអាងធម្មតា ដែលគ្រោងដោយ ក្រុមហ៊ុន HEC មាន ១.២០៧,៦ លានម^3 មានការខុសគ្នា ៩,៨% ដោយសារ ការយកមុខកាត់អាង ខុសពីទីតាំង ពី ក្រុមហ៊ុន HEC នាំឱ្យមានការប្រែប្រួលហានលេខខ្លះ១ (ប្រភព SIHOHYDRO) ។ យោងតាមការការគណនាផ្នែកវិស្វកម្ម ការប្រែប្រួល គឺក្នុងចន្លោះ ± 10% ជាពិសេសការសិក្សាសមិទ្ធិលទ្ធភាពនានា។*

៤.៦.៤.២ ទំនប់អាងស្តុកទឹក (Main Dam)

ទំនប់នេះជាប្រភេទទំនប់ <u>Concrete Face Rock Fill Dam (CFRD)</u> ដែលនៅជញ្ជាំងផ្នែកលើទឹកជាជញ្ជាំងបេតុងដែក ផ្នែកខាងក្រោម ទឹកជាជញ្ជាំងរៀបថ្មភ្នំជាមួយបាយអ និងខាងក្នុងតួទំនប់ បំពេញល្បាយដីឥដ្ឋជាមួយថ្មភ្នំ សាងសង់កាត់ស្ទឹងពោធិ៍សាត់ នៅត្រង់ចំណុច អន្លង់ធ្ម៉មនៅចន្លោះរវាងភ្នំកន្ទង់រ៉ម និងភ្នំសន្ទាំង ដែលវាមានកំពស់រហូតដល់ ១០០,៥ ម (បើធៀប ពីនីវ៉ូបាតស្ទឹង ៨៦ម ដល់នីវ៉ូខ្នងជញ្ជាំងសំណង់ពាក់ព័ន្ធ១៨៦,៥ម) ហើយមានប្រវែងសរុប៦៨៧,២២ ម និងទំនប់បង្ហៀរ (មុខ៣៧ម) ហើយទំនប់នេះ មានសំណង់សិល្បការដូចតទៅដោយមើលពីស្តាំទៅឆ្វេង(មើល DWG 01 និង DRW 03)

1- ទំនប់បង្ហៀរ(Spillway): ទំនប់បង្ហៀរនេះស្ថិតនៅខាងស្តាំតភ្ជាប់ទៅCFRD ដែលនៅខាងលើ មានប្រឡោះទ្វារទឹក២ ហើយមានទីតាំងស្ថិតនៅចំត្រាំងស្ទឹងខាងស្តាំមានមុខទទឹង៣៧ម និងបណ្តោយ៣២,៥ម នីវ៉ូខ្នងលើនៃទំនប់បង្ហៀរមានកម្រិតកំពស់ EL: ១៧៣ម នៅលើទំនប់នេះមាន បំពាក់ទ្វារទឹក ប្រភេទ Radial Gate (ទ្វារទឹករាងពាក់កណ្តាលរង្វង់)ចំនួន២ ដែលមានទំហ ៩,៥ម×១១,៨ម (ទទឹង x កំពស់) និងទ្វារទឹកប្រភេទចតុកោណ(ស្តិបឡក់ Steplock)។ នៅខាងមុនទ្វារទឹក មានប្រឡាយបើកមុខទឹកប្រវែង២៣៧ម ហើយខាងក្រោមផ្លូវទឹកហូរពីទំនប់បង្ហៀរ មានប្រឡាយបង្ហូរទឹកទទឹង ២៣ម ផងដែរ ប្រវែង ២៥០,៨៧ម នៅខាងចុងសំណង់នេះមានសំណង់ចុងប្រឡាយ ប្រវែង ២៨ម រួចភ្ជាប់អាងបំបែកចរន្តទឹកមានប្រវែង ៣០ ម ហើយភ្ជាប់ទៅពោះស្ទឹង ដើម្បីកាត់បន្ថយចរន្តទឹក និងធ្វើឱ្យទឹកហូរចុះខ្សោយ ហើយស្នើកុំឱ្យមានការហូរ

ច្រោះបាតស្ទឹង ឬបាក់ច្រាំង។ កន្លែងសំណង់ចុងប្រឡាយ និងសំណង់បំបែកចរន្តទឹក នេះក៏មានតួនាទីធ្វើឱ្យកម្រិតអុកស៊ីសែន (O_2) រលាយក្នុងទឹកកើនឡើងវិញដែរ ហើយម្យ៉ាងទៀត ធ្វើឱ្យបាត់ក្លិនស្អុយរបស់ទឹក ដែលធ្វើឱ្យជីវសាស្ត្ររស់នៅក្នុងទឹកអាចរស់នៅបានទៀតផង (មើល DWG 01 DWR 05 និង DWG06)។ ការគណនាគ្រោងធ្វើទំនប់បង្ហៀរ គឺគិតតាម ប្រូបាប៊ីលីតេ រយៈពេល ទឹកជំនន់ ១:៥00 ឆ្នាំ តាមការប៉ាន់ប្រមាណរបស់ក្រុមហ៊ុនធារទឹកជំនន់ដែលធំជាងគេ (Probable Maximum Flood) ក្នុងរយៈពេល ១0000 ឆ្នាំ (ក្រោយពេលទឹកបំពេញអាងរួច)នោះ ទឹកនឹងហៀរលើសំណង់នេះ ដោយមានធារទឹក ៨៨២,៤ម^{3}/វិនាទី។ ទំនប់បង្ហៀរនេះគឺធ្វើឡើងដើម្បី ធានា កុំឱ្យជន់លិចតំបន់ ខាងលើទំនប់ធំជាងកម្រិតកំពស់អតិបរមា EL:១៨១,៥ម និងកុំឱ្យគំរាមកំហែងដល់ហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គិសនី ដ៏ទៃទៀត។ ទំនប់នេះនឹងលៃតម្រូវកំពស់ទឹកក្នុងអាងឱ្យនៅត្រឹមកម្រិតនីវ៉ូត្រឹម EL:១៨0ម និងមានសមត្ថភាព អាចដោះទឹកបាន ៨៨២,៤ម^{3}/វិនាទី ហើយធ្វើអំពីបេតុងដែក។ (ទិន្នន័យបានពីក្រុមហ៊ុនKTC)។

2- <u>ទំនប់មេ ជាប្រភេទពាសបេតុងដែកពីមុខ និងបំពេញថ្មភ្នំ</u> (CFRD): ទំនប់នេះ ធ្វើពីបេតុងដែកខាងមុខ (ផ្នែកខាងក្នុងអាង) និងតួវាបំពេញថ្មភ្នំ ដែលមានខ្ពង់លើទទឹង ៧ម កំពស់ ៩៩,៥ម (ធៀបនិងនីវ៉ូបាតស្ទឹងEL: ៨៦ ម) ហើយមានប្រវែង ៦៨៧,២២ម។ នីវ៉ូខ្ពង់ទំនប់លើមានកម្រិតកំពស់ EL:១៨៤ម នៅលើខ្ពង់ទំនប់នេះ មានសំណង់របាំងរលកកំពស់ ១ម ផងដែរ (កម្ពស់ ១00,៥ម ធៀបនិងខ្ពង់លើជញ្ជាំងការពាររលក១ មទៀត)។ (មើល DWR 03 និង DWG 04)

3- សំណង់យកទឹកទៅអូសទូរបីន (Intake Structure): សំណង់នេះ នឹងសាងសង់ផ្នែកខាងស្តាំ ចាប់ប្រឡាយពីមុខទំនប់បង្ហៀរ ដែលមាន១ ប្រឡោះ ដែលបំពាក់ដោយទ្វារទឹក១ ផងដែរ។ សំណង់នេះ មានទទឹង ៩ម ប្រវែងសរុប ៧១ម គិតទាំងប្រឡាយខាងមុខផងដែរ ដែលអាចនាំទឹកទៅអូសទូរបីនមានធារទឹកអតិបរមា ៨0,១២ ម^{3}/វិនាទី ហើយបាតក្រោមសំណង់ទ្វារទឹកមានកម្រិតនីវ៉ូ EL:១៤៨ម និងមានបំពាក់ទ្វារទឹកមួយទំហំ ៦ x ៦ម។ នៅខាងមុនទ្វារទឹក មាន២ប្រឡោះបំពាក់សំណាញ់ សម្រាប់ចាប់កម្ទេច កម្ទីផងដែរ។ (មើល DWG 01 និង DWG 03)

4- បំពង់ទូនេលយកទឹក (Tunnel): សំណង់បំពង់នេះសង់ជារន្ធក្រោមដីបន្តភ្ជាប់ពីសំណង់យកទឹកដល់អាគារថាមពល ដែលមានប្រវែងសរុប ៦.២៤៤ម (គិតចាប់ពីសំណង់យកទឹកចូលដល់អាគារថាមពល)។ សំណង់ទូនេលនេះ ចែកចេញជា៣ផ្នែក គឺផ្នែកទី១ ចាប់ពីសំណង់យកទឹកដល់អាងខ្ជោល ជាបំពង់សំពាធ (Headrace Tunnel) មានប្រវែងសរុប ៥.៥២៤ម ហើយមានអង្កត់ផ្ចិត ៦ម រាងជារង្វង់មូល ធ្វើអំពីបេតុងដែក កំរិតកំពស់បាត នៅខាងមុខមាននីវ៉ូ ១៤៨ម។ ផ្នែកទី២ គឺអាងខ្ជោល (Surge Tank) ដែល តភ្ជាប់ពីបំពង់សម្ពាធទាបនេះ ដែលអាងនេះមានមុខកាត់ក្នុង ទំហំ១៣ម ហើយមានកំពស់៥៨,៨ម (កម្រិតនីវ៉ូខាងលើ EL:២0៣ម និងកម្រិតនីវ៉ូនៅបាតខាងក្រោម EL:១៤៥ម) ធ្វើអំពីបេតុងដែក ដែលតភ្ជាប់ទៅបំពង់ទូនេលនេះ តាមបំពង់១ មានអង្កត់ផ្ចិត៣ម ប្រវែង១១,៩មផងដែរ។ ផ្នែកទី៣ គឺបំពង់ សម្ពាធខ្ពស់ភេនស្តុក (Penstock) មានប្រវែងសរុប ៧0៤ម គិតពី បំពង់ទូនែលសម្ពាធអង្កត់ផ្ចិត ៦ម ដល់ទូរបីន ក្នុងអាគារថាមពល ដែលចែកជា២ផ្នែក គឺផ្នែកបំពង់បេតុង មានប្រវែងសរុប ៦៧៤,២ម មានអង្កត់ផ្ចិតក្នុង ៥ម និងបំពង់ ដែកបែកជាពីរ តភ្ជាប់មុខតំណរវាងអក្សរ Yមានប្រវែងសរុប ៦0ម (៣0ម x២) ហើយមានអង្កត់ផ្ចិតក្នុង៣ម រាងជារង្វង់មូលធ្វើអំពីដែក(Steel Penstock)។ (មើលDWG 01, DRW 07 និង DWG 08)។

5- សំណង់បញ្ជូទឹកសម្រាប់រក្សាលំនឹងបរិស្ថាន (Eco-flow Tunnel) សំណង់នេះនឹងសង់ដាក់បំពង់បង្ហូរទឹកសម្រាប់រក្សាលំនឹងបរិស្ថានខាងក្រោមទំនប់មេ ដែលតភ្ជាប់ពីបំពង់ទូនេលសម្ពាធកន្លែងច្រកចោះរូងទូនេលទី២ (ADIT no.2) ដោយមានធារទឹក ១,៣ម^{3}/វិនាទី ឥតដាច់ទាំងប្រាំងនិងវស្សា។ អង្កត់ផ្ចឹកបំពង់គឺ 0,៥ម នៅកន្លែងនេះ នឹងដំឡើងកូនទូរបីនតូចមួយសម្រាប់ជលិតអគ្គិសនីផងដែរ ដែលវាមានកម្លាំង ៨00kW និងជលិតអគ្គិសនីបាន ៦,១៩លាន kWh ឆ្នាំ។ ពីទំនប់មេ ដល់កន្លែងដែលទឹកហូរចូលស្ទឹងពោធិ៍សាត់មានប្រវែង៣គ.ម (មើលDWG 01)។

6- <u>អាគារថាមពល(Power House)</u> សំណង់នេះនឹងសង់នៅខាងក្រោមទំនប់មេវាស់តាមដងទឹងមានប្រវែង ៩,២គ.ម ដែលមានទំហំ ២,៥ ហ.ត និងកំពស់ ៣១ម ដែលបំពាក់ ដោយទូរប៊ីន២ (៤០MWx ២)កម្លាំងសរុបមាន ៨០MW ភ្ជាប់ពីបំពង់ទូនេលសម្ពាធ ដែលអាចបញ្ចោញទឹកបាន ៨០,១២ម^{3}, វិនាទី (៤០,០៦ ម^{3}/វិនាទី×២)។ នៅទីតាំងនេះមាន វាលសម្រាប់ តំឡើងត្រង់ស្វ៊ីមមើផងដែរ។ (មើល DWG 01និង DWG 07)

<u>សម្គាល់:</u> *វារីអគ្គិសនីនេះផលិតអគ្គិសនី ជាមធ្យមក្នុងមួយថ្ងៃ១៣ម៉ោង ទាំងប្រាំងនិងវស្សា និងតាមតម្រូវការរបស់ EDC។ ការប៉ាន់ប្រមាណម៉ោងផលិតអគ្គិសនីក្នុងមួយឆ្នាំគឺ ៤.៥៥៨ ម៉ោង។*

7- <u>ទំនប់បណ្តោះអាសន្ន (Coffer Dams)</u> សំណង់នេះ សង់ខាងលើ និងខាងក្រោមទំនប់មេ មានលក្ខណៈសង់ជា បណ្តោះអាសន្ននៅពេលសាងសង់ទំនប់មេ (ទំនប់វារីអគ្គិសនី) រួចសំណង់ទាំង២នេះ នឹងរំលាយចោលវិញ។ ទំនប់បណ្តោះអាសន្ននេះសង់ពីថ្មល្បាយដី។ ទំនប់នេះមានតួនាទីសម្រាប់ទប់ទឹកមិនឱ្យចូលទៅការដ្ឋាន សាងសង់ទំនប់មេ ដែលទំនប់ខាងលើមាននីវ៉ូខ្ពង់លើ EL:១១៨ម មានប្រវែង ៣៥៨,៣ម កំពស់ ៣៥ម និងទំនប់បណ្តោះអាសន្នខាងក្រោម មាននីវ៉ូខ្ពង់លើEL:១០០ម ប្រវែង៩៦,៣ម កំពស់១៩ម ហើយវាទាំង២មានទទឹងខ្ពង់លើ នីមួយៗ ៨ ម។

8- <u>សំណង់ពង្វាងទឹកបណ្តោះអាសន្ន (Diversion Tunnel)</u> សំណង់នេះ សង់សម្រាប់ពង្វៀងទឹកស្ទឹងមកខាងក្រោមទំនប់ Downstream Coffer Dams នៅពេលសាងសង់ទំនប់មេ។ សំណង់នេះជារន្ធទូនេល ដែលសង់នៅច្រាំងខាងឆ្វេងស្ទឹង មានប្រវែង ៥៥០,៣ម ដែលមានមុខកាត់ជាអក្សរ U ផ្ទាប់ ១០ x ១១ម (ទទឹងx កម្ពស់)ហើយមាននីវ៉ូបាតខាងមុខ EL: ៩០ម វាមានសមត្ថភាពអាចដោះទឹកបាន ១.៤១០ ម^{3}/វិន. (មើល DWR 01)។

<u>បញ្ជាក់</u>: ការគ្រោងរាល់សំណង់បេតុងទាំងអស់ មានអាយុកាល៥០ឆ្នាំ។ ក្នុងដំណាក់កាលប្រតិបត្តិគម្រោង កំណកល្បាប់ក្នុងអាងតាមការប៉ាន់ប្រមាណរបស់ SINOHYDRO ក្នុងរយៈពេល ១០០ ឆ្នាំ វានឹងកើនដល់រយៈកម្ពស់ EL: ១១៥,៤ ម ដែលតិចជាងរយៈកម្ពស់ EL: ១៦០ម ងាប់របស់អាង (កម្ពស់ទឹកមិនអាចដំណើរការផលិតអគ្គិសនី)។ ដូចនេះ សំណង់ បញ្ចោញកករដើម្បីលាងអាងមិនចាំបាច់សាងសង់ឡើយ។ រាល់ទំហំនានា របស់សំណង់ទាំងអស់ ដកស្រង់ពី គំនូរបច្ចេកទេសជា AutuCAD File និង របាយការណ៍បច្ចុប្បន្នភាពសមិទ្ធលទ្ធភាពដែលផ្តល់ដោយម្ចាស់គម្រោង។ ដូចនេះ កំណកល្បាប់ក្នុងអាងមិនមានការរាំងស្ទះ ឬថយចុះ នូវការផលិតអគ្គិសនីនោះទេ។ ក្នុងករណី មានការហូរច្រោះកើនឡើងពីតំបន់ផ្ទៃរងទឹកភ្លៀងខាងលើ គឺគេអាចប្រើប្រាស់រូងពង្វាងទឹកនេះ ព្រោះវាមាននីវ៉ូបាត៩០ម ដែលនីវ៉ូបាតស្ទឹង ៨៦ម។

៨.៦.៤ ខ្សែបញ្ជូនអគ្គិសនី (Transmission Line)

ការផលិតថាមពលអគ្គិសនីសរុបក្នុង១ឆ្នាំ ៣៦៧,១២លាន kWh គឺនៅអាគារថាមពលត្រូវបញ្ជូនតាមខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០kV ពីអាគារថាមពល ដល់ទៅភ្ជាប់និងខ្សែបណ្តាញ២៣០គ.វ៉ ពោធិ៍សាត់-អូរសោម ដែលមានប្រវែងសរុបប្រមាណ ៥ គ.ម។

ចំពោះបង្គោលខ្សែចម្លងទាំងនេះមានកំពស់ទៅតាមរយៈកំពស់ដី គឺចាប់ពីប្រមាណ ២០ម ទៅ ៤០ម ដែលយោងទៅតាមស្ថាន ភាពដីទំនាប ឬ ភ្នំចំងាយប្រឡោះពីបង្គោលមួយទៅបង្គោលមួយគឺ ២៥០ ទៅ ៥០០ម (មើលរូបទី២ ខាងក្រោម)។ ការសាងសង់ បង្គោលទាំងនោះតម្រូវការផ្ទៃដីសម្រាប់បង្គោល១ គឺទំហំ ២២៥ម^{២} (១៥ម x ១៥ម)ហើយចំនួនបង្គោលភ្លើងសរុបមាន ១៣ បង្គោល។

ដើម្បីធានាសុវត្ថិភាព និងនិរន្តរភាពក្នុងការបញ្ជូនអគ្គិសនីដល់អ្នកប្រើប្រាស់នៅតាមបណ្តាខេត្តនានាដូចជា ខេត្តពោធិ៍សាត់ បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ កណ្តាល និងរាជធានីភ្នំពេញ (តាមផែនការមេនៃខ្សែបញ្ជូន ដែលមានតង់ស្យុងខ្ពស់ ២៣០គីឡូវ៉ុល ភ្នំពេញ-បាត់ដំបងរបស់ក្រសួងរ៉ែ និងថាមពល) គន្លងខ្សែបញ្ជូនអគ្គិសនីនេះ នឹងត្រូវគណនា ដោយគិតពីសុវត្ថិភាពកុំឱ្យគ្រោះថ្នាក់ ដល់មនុស្ស សត្ត គឺមានទំហំ១៥ម ចេញពីអក្សរ៌គន្លង (សរុប ៣០ម) និងត្រូវសំអាតដើមឈើដូចរូបទី ១ ខាងក្រោម (កំពស់ឈើមិនលើសពី ៣ម)។

<u>សម្គាល់</u>: *នៅក្រោមតំបន់ខ្សែបញ្ជូលអគ្គិសនីតង់ស្យុងខ្ពស់នេះ (ទទឹង ២០ម) ដើមឈើ ឬ ដំណាំ ដែលមានកំពស់ធំជាង ៣ម មិនត្រូវបានអនុញ្ញាតឱ្យមានក្នុងតំបន់នេះទេ។ ចំពោះលំនៅឋាន ឬការសន់នៅរបស់ប្រជាពលរដ្ឋជាប្រចាំនៅក្នុងតំបន់នេះ ក៏ត្រូវបានហាមឃាត់ផងដែរ (មើលរូប១ខាងក្រោម)។ យោងទៅតាមការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនេះបានបង្ហាញថា ភ្ជានលំនៅឋានរបស់ ប្រជាពលរដ្ឋស់នៅក្រោមតំបន់ខ្សែបញ្ជូនអគ្គិសនីនេះទេ (សិក្សាខែតុលា ដល់ខែកុម្ភៈ ឆ្នាំ២០១៧)។*



រូបទី១: តំបន់សុវត្ថិភាព និងតំបន់តាមគន្លងខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់(៣០ម)



ប្រភេទ SZC ប្រភេទ SJC & SDJ

Draft

រូបទី២: ខ្សែបញ្ជូនអគ្គិសនី២៣០គ.វ៉ុ
Double Circuit

៨.៦.៦ មធ្យោបាយ និងសម្ភារ-ឧបករណ៍សម្រាប់សាងសង់គម្រោង

ក្រុមហ៊ុនគ្រោង នឹងប្រើប្រាស់គ្រឿងចក្រសំខាន់មួយចំនួនក្នុងពេលសាងសង់គម្រោង ដូចមានរាយនាមខាងក្រោម (ចំពោះ ឧបករណ៍ផ្សេងៗទៀត និងបញ្ជាក់នៅពេលក្រោយ):

តារាង ៤- ៣: គ្រឿងចក្រ និងឧបករណ៍សម្រាប់សាងសង់គម្រោង

ប្រភេទគ្រឿងចក្រ (Equipments)		សមត្ថភាព	ចំនួន
1.	ត្រាក់ទ័រឈូសដី BULLDOZER	19 ton	5
2.	ត្រាក់ទ័រឈូសដី BULLDOZER	32 ton	5
3.	ត្រាក់ទ័រចូកដី BACKHOE	0.7 m^3	2
4.	ត្រាក់ទ័រលើកសម្ភារ WHEEL LOADER	1.72 m^3	4
5.	ត្រាក់ទ័រលើកសម្ភារ WHEEL LOADER	3.50 m^3	2
6.	ម៉ាស៊ីនលើកដាក់សម្ភារ CRAWLER LOADER	1.72 m^3	12
7.	រថយន្តដឹកដី DUMP TRUCK	6 ton	4
8.	រថយន្តដឹកដី DUMP TRUCK	10.5 ton	20
9.	រថយន្តដឹកដី DUMP TRUCK	15 ton	5
10.	រ៉ូឡារ៉ញ្ជ៉ VIBRO ROLLER	10 ton	2
11.	ម៉ាស៊ីនស្ទាន LEG DRILL	2.7 m^3/min	6
12.	ម៉ាស៊ីនស្ទាន CRAWLER DRILL	17 m^3/min	15
13.	ម៉ាស៊ីនខ្យល់ AIR COMPRESSOR	7.1 m^3/min	2
14.	ម៉ាស៊ីនខ្យល់ AIR COMPRESSOR	10.3 m^3/min	15
15.	ម៉ាស៊ីនខ្យល់ AIR COMPRESSOR	17 m^3/min	2
16.	ម៉ាស៊ីនខ្យល់ AIR COMPRESSOR	25.5 m^3/min	2
17.	ត្រាក់ទ័រលើកសម្ភារ SIDE DUMP LOADER	1.40 m^3	2
18.	ត្រាក់ទ័រខួងគ្រឹះ BORING MACHINE	50 m × 200 m	10
19.	ម៉ាស៊ីនស្ទូប GROUTING PUMP	40 ~ 125ℓ/min	4
20.	ម៉ាស៊ីនលាយ GROUTING MIXER	190ℓ×2	4
21.	រថយន្តបូម CON'C PUMP CAR	80 m^3/hr	4
22.	រថយន្តបូម CON'C PUMP	20 ~ 26 m^3/hr	2
23.	គ្រឿងចក្រលាយបេតុង CON'C MIXER TRUCK	6.0 m^3	6
24.	រថយន្តដឹកទឹក WATER TANK	5.5 m^3	10
25.	គ្រឿងចក្រស្ទូច TRUCK CRANE	10 ton	2
26.	គ្រឿងចក្រស្ទូច TRUCK CRANE	30 ton	2
27.	CON'C FACE SLIP FORM	1.5 m × 15 m	2
28.	RBM	ø 2.4	1
29.	ម៉ាស៊ីនរ៉ែកទាញ WINCH	15 kW	2
30.	ឧបការណ៍បាញ់ SHOTCRETE GUN	ALIVA 260	4
31.	ឧបការណ៍ទប់ដី SLIDING STEEL FORM	L = 12.0 m, D4.6	3
32.	ឧបការណ៍ទប់ដី SLIDING STEEL FORM	L = 3.0 m, D4.6	1
33.	គ្រឿងចក្រគៀដី MOTOR GRADER	3.6 m	1
34.	រ៉ូឡារ៉ញ្ជ៉ VIBRATING ROLLER	10 ton	1
35.	រ៉ូឡកង់ជ័រ TIRE ROLLER	8 ~ 15 ton	1
36.	គ្រឿងចក្រកិនថ្ម CRUSHER	150 ton	1

ក្នុងការសាងសង់គម្រោងវារីអគ្គិសនីនេះ តម្រូវការសម្ភារ មានដូចតទៅ ៖

តារាង ៤- ៤: សម្ភារ និងវត្ថុធាតុដើមសម្រាប់សាងសង់គម្រោង

បរិយាយ		ឯកតា	ចំនួន	ទីតាំងយក ឬទិញសម្ភារ
Item		Unit	Total Quantity	Location of taking construction material
ស៊ីម៉ង់ត៍	Cement	10^3 t	៥០.៧	មិនទាន់បានកំណត់យកពីណានៅឡើយទេ
ខ្សាច់	Sand	10^3 m^3	៨២.៣	
ថ្មលាយបេតុង	Gravel	10^3 m^3	៦៩.៣	ក្នុងតំបន់គម្រោង
ដែកសរសៃ	Steel Bar	10^3 t	១៥.៨	មិនទាន់បានកំណត់យកពីណានៅឡើយទេ
បេតុង	Concrete	10^3 t	១៦.៩៥	

បញ្ជាក់: ទិន្នន័យបានពីក្រុមហ៊ុន KTC ។ បរិមាណខាងលើនេះអាចមានការប្រែប្រួល ទៅតាមការគ្រោងលម្អិតទៀត។

Draft

៨.៦.៧ កម្លាំងពលកម្ម (Labors)

ក្រុមហ៊ុនមានគម្រោងផែនការជ្រើសរើសបុគ្គលិក-កម្មករ បរទេស និងពលករកម្ពុជា ទាំងក្នុងពេលសាងសង់ និងប្រតិបត្តិថែទាំ គម្រោងការជ្រើសរើសនេះ នឹងផ្តល់អាទិភាពចំពោះប្រជាជន ដែលរស់នៅក្បែរតំបន់គម្រោង ដូចជាអ្នកស្រុករស់នៅឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ជាដើម។

១- <u>កំឡុងពេលសាងសង់</u>

ផែនការរបស់ក្រុមហ៊ុនក្នុងការជ្រើសរើសបុគ្គលិក-កម្មករ ក្នុងពេលសាងសង់របស់គម្រោងទាំងមូល រួមទាំងការសាងសង់ប្រព័ន្ធ ខ្សែបញ្ជូនអគ្គិសនី ដែលមានរយៈពេល៤,៥ឆ្នាំ នោះគឺត្រូវការមនុស្សរហូតទៅដល់ ៤០០នាក់ ក្នុងនោះបុគ្គលិក-កម្មករបរទេសចំនួន១០០នាក់ (ក្នុងនោះវិស្វករចំនួន៨០នាក់)និងពលករខ្មែរជុំវិញតំបន់គម្រោងចំនួន៣០០នាក់។ ចំណែកឯពលកម្មសម្រាប់ការសាងសង់ប្រព័ន្ធខ្សែចម្លង ពីអាគារថាមពល ភ្ជាប់ទៅខ្សែ២៣០ គ.វ៉ អូរសោម-ពោធិ៍សាត់ ចំនួន ៤០ នាក់ ក្នុងនោះប្រជាពលរដ្ឋ ជុំវិញតំបន់គម្រោងចំនួន ៣០នាក់ និងបុគ្គលិក-កម្មករបរទេសចំនួន១០នាក់។

សម្គាល់: *ផែនការរៀបចំគម្រោងមុនការសាងសង់ ៩ខែ ការសាងសង់គម្រោង មានរយៈ ពេល ៤ ឆ្នាំ។ ចំពោះ ព័ត៌មានលម្អិត អំពី តាងរាងប្រាក់បៀវត្សបុគ្គលិក-កម្មករទាំងអស់ មិនទាន់បានគ្រោងលម្អិតនៅឡើយទេ ព្រោះគម្រោងនេះមិនទាន់បានការអនុញ្ញាតឱ្យធ្វើការអភិវឌ្ឍពីរាជរដ្ឋាភិបាលកម្ពុជាទេ ហើយម្ចាស់គម្រោង ក៏មិនទាន់បានចុះបញ្ជីជាផ្លូវការនៅក្រសួងពាណិជ្ជកម្មផងដែរ។ នៅពេលដែល ម្ចាស់គម្រោងទទួលបានការអនុញ្ញាត ឱ្យសាងសង់គម្រោងនេះ នោះពេល រៀបចំ របាយការណ៍ការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថានរបស់គម្រោងនិងមានបញ្ជាក់វាផងដែរ។*

២- កំឡុងពេលប្រតិបត្តិ និងថែទាំ

ចំនួនពលកម្មក្នុងកំឡុងពេលប្រតិបត្តិ និងថែទាំសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធគម្រោង: ផែនការរបស់ក្រុមហ៊ុន នឹងត្រូវក្នុងការជ្រើសរើសបុគ្គលិកក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំរបស់គម្រោងសម្រាប់រយៈពេលប្រតិបត្តិ និងថែទាំ មានចំនួន៥០នាក់ ក្នុងនោះបុគ្គលិក ខ្មែរ ចំនួន២៥នាក់ និងបុគ្គលិកបរទេស ចំនួន៣០នាក់ ។

- ប្រធានអ្នកចាត់ចែងការ រដ្ឋបាល និងផលិតកម្ម	ជនជាតិបរទេស	១៥នាក់	ខ្មែរ គ្មាន
- បុគ្គលិកផ្នែកវិស្វកម្មទឹក	ជនជាតិបរទេស	០២នាក់	ខ្មែរ ១០នាក់
- បុគ្គលិកផ្នែកបញ្ជារ និងដំណើរការ	ជនជាតិបរទេស	០៥នាក់	ខ្មែរ ០៥នាក់
- បុគ្គលិកផ្នែកថែទាំ និងជួសជុល	ជនជាតិបរទេស	៧នាក់	ខ្មែរ ០៥នាក់
- បុគ្គលិកផ្នែកព័ត៌មាន	ជនជាតិបរទេស	០១នាក់	ខ្មែរ ០៥នាក់

<u>បញ្ជាក់:</u> ចំនួនខាងលើនេះ អាចមានការកែប្រែដោយយោងតាមការសិក្សាលម្អិតបន្ថែមទៀត របស់ក្រុមហ៊ុន។

បុគ្គលិកសម្រាប់គ្រប់គ្រងថែទាំប្រព័ន្ធខ្សែបញ្ជូនអគ្គិសនី ពីអាគារថាមពលទៅបណ្តាញ ២៣០ គ.វ៉ របស់ក្រុមហ៊ុនចិន ក្រុមហ៊ុនមានផែនការ ជ្រើសបុគ្គលិក ក្នុងកំឡុងពេលប្រតិបត្តិ និងថែទាំរយៈពេល៣៥ឆ្នាំ ចំនួន១៣នាក់ ក្នុងនោះ បុគ្គលិកខ្មែរ ចំនួន ០៦នាក់ និងបុគ្គលិក បរទេស ចំនួន៧នាក់ ដែលត្រូវបែងចែកទៅតាមការងារ ដូចខាងក្រោម ៖

- ប្រធានអ្នកចាត់ចែង និង បុគ្គលិកផ្នែករដ្ឋបាល	ជនជាតិបរទេស ០២ នាក់	ខ្មែរ ០១នាក់
- បុគ្គលិកផ្នែកបញ្ជារ និងដំណើរការ	ជនជាតិបរទេស ០២ នាក់	ខ្មែរ ០២នាក់
- បុគ្គលិកផ្នែកថែទាំ និងជួសជុល	ជនជាតិបរទេស ០២ នាក់	ខ្មែរ ០២នាក់
- បុគ្គលិកផ្នែកព័ត៌មាន	ជនជាតិបរទេស ០១ នាក់	ខ្មែរ ០១នាក់

៣- ប្រាក់បៀវត្សបុគ្គលិក-កម្មករ

បុគ្គលិក និងកម្មករសំរាប់ដំណាក់កាលសាងសង់ និងប្រតិបត្តិ និងថែទាំ គឺមានទាំងជនជាតិខ្មែរ និងចិន។ តម្លៃឯកតានៃប្រាក់ពលកម្ម គឺគិតបញ្ចូលតាំងពីប្រាក់ឈ្នួលជាមូលដ្ឋាន, ប្រាក់ឈ្នួលបន្ថែម, អត្ថប្រយោជន៍សង្គម, ប្រាក់សំរាប់ធានារ៉ាប់រងដល់កម្មករនិយោជិត ត្រូវបានគណនាយ៉ាងទូលំទូលាយអាស្រ័យលើប្រភេទនៃការងារ។

កម្មករជំនាញជាន់ខ្ពស់ 7.15 USD/ម៉ោង	កម្មករជំនាញ 4.37 USD/ម៉ោង
កម្មករពាក់កណ្តាលជំនាញ 2.53 USD/ម៉ោង	កម្មករអត់ជំនាញ 1.16 USD/ម៉ោង

៨.៦.៨ តម្រូវការប្រើប្រាស់ទឹក និងថាមពល (Water and Energy Consumption)

ក.ការប្រើប្រាស់ទឹក

ការប្រើប្រាស់ទឹកមានពីរប្រភេទ គឺ(១)ការប្រើប្រាស់ទឹកសម្រាប់បរិភោគ និង(២)ការប្រើប្រាស់សម្រាប់ងូត បន្ទប់

ទឹក និងដាំស្ល និងលាយបេតុង។ ចំពោះទឹកសម្រាប់ផឹកគឺប្រើទឹកបរិសុទ្ធ ដប និងធុង។ ចំណែកឯ ទឹកប្រើប្រាស់សម្រាប់ងូត ដាំស្ល បន្ទប់ទឹកនិងលាងសំអាតផ្សេងៗ គឺប្រើប្រាស់ទឹកស្ទឹងពោធិ៍សាត់ ដោយមានម៉ាស៊ីនបូម ដាក់ស៊ីទែនខ្ពស់រួចចែកចាយតាមទុយូ នៅតំបន់ខ្ពស់ ដឹកតាមរថយន្តស៊ីទែន ហើយស្តុកក្នុងអាង/ធុងស្តុក ទឹក។ ដូចគ្នាដែរចំពោះទឹកសម្រាប់លាយបេតុងគឺយកពីស្ទឹងពោធិ៍សាត់។ បរិមាណ ប្រើប្រាស់ទឹកសម្រាប់បម្រើឱ្យការសាងសង់គម្រោងសរុបមានប្រមាណ ៨០០ ម^{3} ទៅ១០០០ម^{3} ក្នុងមួយថ្ងៃ។

នៅក្នុងដំណាក់កាលប្រតិបត្តិគម្រោងបរិមាណប្រើប្រាស់ទឹក ថយមកត្រឹម ប្រមាណពី៧៥ ទៅ ៨៥ម^{3}/ថ្ងៃ ប្រភពទឹក យកពីអាងទឹករបស់វារីអគ្គិសនី សម្រាប់ងូត បន្ទប់ទឹក និងដាំស្ល និងលាងសំអាតផ្សេងៗ។ ចំណែកឯ ទឹកបរិភោគគឺទឹកបរិសុទ្ធ ដប ឬធុងដែលមានអនាម័យខ្ពស់។

ខ.ការប្រើថាមពល

ការប្រើប្រាស់ថាមពលអគ្គិសនីមានពីរប្រភពគឺ (១) ពីម៉ាស៊ីនភ្លើងដែលមានប្រអប់ការពារសំឡេង (Silent Generator Type) (២)ពីខ្សែបណ្តាញអគ្គិសនី ដែលយកពីបណ្តាញអូរសោម។

បញ្ជាក់: *បរិមាណ នៃការប្រើប្រាស់ថាមពលអគ្គិសនី គឺមិនទាន់បានគ្រោងលម្អិតនៅឡើយពីព្រោះគម្រោងនេះក្នុងកំរិតសិក្សាលទ្ធភាពដើម្បីប៉ាន់ប្រមាណថវិកាសម្រាប់វិនិយោគពីបរទេស ហើយនៅដំណាក់គ្រោងគម្រោងលម្អិតនិងធ្វើការបញ្ជាក់នៅពេលក្រោយដោយ ទីប្រឹក្សាបច្ចេកទេស។*

៨.៦.៩ ការប៉ាន់ប្រមាណតម្លៃនៃគម្រោង (Project Cost Estimation)

គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ មានអានុភាពអគ្គិសនី ៨០ MW ហើយត្រូវការរយៈពេលសាងសង់ ៤ឆ្នាំ (គម្រោង នេះមិនទាន់ចាប់ផ្តើមការសាងសង់នៅឡើយទេ)។ តាមការគណនារបស់ក្រុមហ៊ុន SIHOHYDRO គម្រោងនេះមានតម្លៃ វិនិយោគសរុប ២៣២.២១០.០០០(ពីរយសាមសិបពីរលាន ពីរយដប់ពាន់) ដុល្លារអាមេរិក ក្នុងនោះមានទុនសម្រាប់កិច្ចការពារបរិស្ថានចំនួន ៨.៦៨៩.៣៧៦ ដុល្លារអាមេរិក ផងដែរ។ ដូចមានរៀបរាប់ក្នុងតារាងខាងក្រោម ៖

តារាង ៤- ៥: ការប៉ាន់ប្រមាណតម្លៃនៃគម្រោង និងផែនការចំណាយក្នុងពេលសាងសង់គម្រោង

#	Project	year 1	year 2	year 3	year 4	Total (10,000USD)
1	Static investment	3456.3	5935.5	7588.1	4414.9	21394.8
2	Reserve funds for price difference		118.7	306.6	270.2	695.5
3	Construction interrests	59.3	223.2	466.1	382.1	1130.7
4	Total investment not including circulating funds	3515.6	6277.5	8360.8	5067.2	23221.1

សម្គាល់ *៖ ប្រភពទិន្នន័យរបាយការណ៍ ធ្វើបច្ចុប្បន្នភាព សមិទ្ធលទ្ធភាពគម្រោងឆ្នាំ ២០១៧។*

៨.៦.១០ ខ្សែសង្វាក់ផលិតកម្មចំពោះការសាងសង់វារីអគ្គិសនី

៨.៦.១០.១ ខ្សែចង្វាក់ផលិតកម្ម នៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គិសនី

គំនូសបំព្រួញនៃខ្សែសង្វាក់ផលិតកម្ម របស់គម្រោងវិនិយោគទុនលើវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ ខេត្តពោធិ៍សាត់



តារាង ៤- ៦: សម្ភារៈបំពាក់/តំឡើង សម្រាប់ផលិតអគ្គិសនី របស់គម្រោង

បរិយាយ		ឯកតា	ចំនួន	សម្គាល់
Item		Unit	Total Quantity	Remarks
ទូរប៊ីនប្រើចរន្តទឹក HL(184)-LJ-225	Hydraulic turbine HL(184)-LJ-225	set	2	ទំងន់ 115t/unit
ទូរនប្រើចរន្តទឹក (800kW)	Hydraulic turbine (800 kW)	set	1	
ទូរបញ្ជា YWT-80-6.3 សម្រាប់ទូប៊ីន	Governor YWT-80-6.3	set	2	
ប្រដាប់វាស់សម្ពាធប្រេង HYZ-1.6-4	Oil pressure unit HYZ-1.6-4	set	2	
គ្រឿងបញ្ជា ដោយស្វ័យប្រវត្តិ	Elements of automated equipment	set	2	
ប្រដាប់ត្រួតពិនិត្យ តាម on-line	Unit on-line monitoring	set	2	បញ្ជាពីចម្ងាយ
ម៉ាស៊ីនផលិតអគ្គិសនី SF40-18/4100	Generator SF40-18/4100	set	2	ទំងន់ 240t/unit, ភ្ជាប់ជាមួយទូរប៊ីន
ម៉ាស៊ីនផលិតអគ្គិសនី (800 kW)	Generator (800 kW)	set	1	ភ្ជាប់ជាមួយទូរប៊ីន
ប្រដាប់ ម៉ូយ ម៉ាស៊ីនផលិតអគ្គិសនី	Exciter	set	2	
គ្រឿងបញ្ជា ដោយស្វ័យប្រវត្តិ	Elements of automated equipment	set	2	

ប្រភព: *ការសិក្សាបច្ចុប្បន្នភាព សមិទ្ធិលទ្ធភាព ឆ្នាំ ២០១៧*

៤.៦.១០.២ ខ្សែចង្វាក់ផលិតកម្មនៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គ.វ៉ុ

គំនូសបំព្រួញនៃខ្សែសង្វាក់ផលិតកម្ម របស់គម្រោងវិនិយោគទុនលើវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ ខេត្តពោធិ៍សាត់



តារាង ៤- ៧: សម្ភារៈបំពាក់/តំឡើង សម្រាប់ការបញ្ជូនអគ្គិសនី របស់គម្រោង

បរិយាយ		ឯកតា	ចំនួន	សម្គាល់
Item		Unit	Total Quantity	Remarks
កាប៊ីន សៀគ្វីផ្តាច់អគ្គិសនី 11kV	Generator circuit breaker cabinet 11kV	set	2	4000A
កាប៊ីន សៀគ្វីផ្តាច់អគ្គិសនីសម្រាប់ត្រង់ហ្ស្វូម៉ារ	Service transtormer circuit breaker cabinet 11kV	set	2	4000A
កាប៊ីន ត្រង់ហ្ស្វូម៉ារតង់ស្យុង និង សម្រាប់ចាប់រន្ទះ 11kV	Voltage transformer and lightning arrester cabinrt 11kV	set	2	4000A
ត្រង់ហ្ស្វូម៉ារ SCB10-800, 10.5/0.4kV	Service transformer SCB10-800, 10.5/0.4kV	set	2	
ត្រង់ហ្ស្វូម៉ារចូល SCB10-800, 10.5/0.4kV	Incoming transformer SCB10-800, 10.5/0.4kV	set	2	
បង្គោលអគ្គិសនី (ដែកហ្ស្វេម)	Electrical tower	tower	13	
ខ្សែកាបអគ្គិសនី 10kV	Power cable 10kV	km	1.8	
ខ្សែកាបអគ្គិសនី LV 0.6/1kV	LV cable 0.6/1kV	km	22	
ខ្សែកាបអគ្គិសនី 230kV	Power cable 230kV	km	80	

ប្រភព: *ការសិក្សាបច្ចុប្បន្នភាព សមិទ្ធិលទ្ធភាព ឆ្នាំ ២០១៧។*

Draft

៤.៦.១១ ចំណូល ចំណាយរបស់ក្រុមហ៊ុន

យោងតាមការសិក្សាបច្ចុប្បន្នភាពសមិទ្ធិលទ្ធគម្រោងឆ្នាំ ២០១៧ ដែលសិក្សាដោយក្រុមហ៊ុន SINOHYDRO របស់ចិនបានបង្ហាញថា គម្រោងនេះក្រោយពេលដំណើរការបាន៣៩ឆ្នាំ មានប្រាក់ចំណូលពីការលក់អគ្គិសនីប្រមាណ ១.០១១.២៣៧.០០០ដុល្លាអាមេរិក ចំណាយសរុបប្រមាណ ៦៩៥.៨០៣.០០០ ដុល្លាអាមេរិក និងប្រាក់ចំណេញសរុបប្រមាណ ៣១៥.៤៣៤.០០០ ដុល្លាអាមេរិក (លម្អិត មើលតារាងខាងក្រោម)៖

តារាង ៤- ៨: ការប៉ាន់ប្រមាណ ចំណូល ចំណាយ របស់គម្រោង រយៈពេលសរុប ៣៩ឆ្នាំ ក្នុងនោះរយៈពេល៤ឆ្នាំសម្រាប់សាងសង់គម្រោង (ខ្ពាតជា ១០.០០០ ដុល្លារអាមេរិក)

ល.រ	បរិយាយ	ឆ្នាំទី 1	ឆ្នាំទី 2	ឆ្នាំទី 3	ឆ្នាំទី 4	ឆ្នាំទី 5	ឆ្នាំទី 6	ឆ្នាំទី 7	ឆ្នាំទី 8	ឆ្នាំទី 9	ឆ្នាំទី 10	ឆ្នាំទី 11	ឆ្នាំទី 12	ឆ្នាំទី 13	ឆ្នាំទី 14	ឆ្នាំទី 15	ឆ្នាំទី 16	ឆ្នាំទី 17	ឆ្នាំទី 18	ឆ្នាំទី 19	ឆ្នាំទី 20
1	ចំណូល	0	0	0	0	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2
1.1	ចំណូលពីការលក់អគ្គិសនីប្រចាំឆ្នាំ	0	0	0	0	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2
1.2	ចំណូលផ្សេងៗ	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0
2	ចំណាយ	1054.7	1883.2	2508.2	1541.2	2811.8	2811.8	2811.8	2811.8	2811.8	2811.8	2811.8	2811.8	2811.8	2811.8	2811.8	2811.8	1616	1202.8	1202.8	1202.8
2.1	មូលធនរបស់គម្រោង	1054.7	1883.2	2508.2	1541.2	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0
2.2	ចំណាយការណេះបង់ប្រាក់កម្ចី	0	0	0	0	1040.7	1091.7	1145.2	1201.3	1260.2	1321.9	1386.7	1454.6	1525.9	1419.9	1475.5	1533.4	397.7	0	0	0
2.3	ចំណាយការប្រាក់កម្ចី	0	0	0	0	798.6	747.6	694.1	638	579.1	517.4	452.6	384.7	313.4	238.6	169.1	96.8	21.6	2.1	2.1	2.1
2.4	ការជំនាំប្រតិបត្តិកម្រោង	0	0	0	0	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5
2.6	ពន្ធលើប្រាក់ចំណូល	0	0	0	0	0	0	0	0	0	0	0	0	0	180.8	194.7	209.2	224.2	228.1	228.1	228.1
3	តុល្យភាព (ចំណូល-ចំណាយ)	-1054.7	-1883.2	-2508.2	-1541.2	77.4	77.4	77.4	77.4	77.4	77.4	77.4	77.4	77.4	77.4	77.4	77.4	1273.2	1686.5	1686.5	1686.5

ល.រ	បរិយាយ /ឆ្នាំ	ឆ្នាំទី 21	ឆ្នាំទី 22	ឆ្នាំទី 23	ឆ្នាំទី 24	ឆ្នាំទី 25	ឆ្នាំទី 26	ឆ្នាំទី 27	ឆ្នាំទី 28	ឆ្នាំទី 29	ឆ្នាំទី 30	ឆ្នាំទី 31	ឆ្នាំទី 32	ឆ្នាំទី 33	ឆ្នាំទី 34	ឆ្នាំទី 35	ឆ្នាំទី 36	ឆ្នាំទី 37	ឆ្នាំទី 38	ឆ្នាំទី 39	Total
1	ចំណូល	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	101,123.70
1.1	ចំណូលពីការលក់អគ្គិសនីប្រចាំឆ្នាំ	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	2889.2	101,123.70
1.2	ចំណូលផ្សេងៗ	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0
2	ចំណាយ	1202.8	1202.8	1202.8	1202.8	1202.8	1202.8	1202.8	1202.8	1202.8	1202.8	1202.8	1202.8	1202.8	1202.8	1357.6	1357.6	1357.6	1357.6	1357.6	69580.3
2.1	មូលធនរបស់គម្រោង	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	6987.3
2.2	ចំណាយការណេះបង់ប្រាក់កម្ចី	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	0	16254.8
2.3	ចំណាយការប្រាក់កម្ចី	2.1	2.1	2.1	2.1	2.1	2.1	2.1	2.1	2.1	2.1	2.1	2.1	2.1	2.1	2.1	2.1	2.1	2.1	2.1	5698.6
2.4	ការជំនាំប្រតិបត្តិកម្រោង	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	972.5	34038.3
2.6	ពន្ធលើប្រាក់ចំណូល	228.1	228.1	228.1	228.1	228.1	228.1	228.1	228.1	228.1	228.1	228.1	228.1	228.1	228.1	382.9	382.9	382.9	382.9	382.9	6601.4
3	តុល្យភាព (ចំណូល-ចំណាយ)	1686.5	1686.5	1686.5	1686.5	1686.5	1686.5	1686.5	1686.5	1686.5	1686.5	1686.5	1686.5	1686.5	1686.5	1531.7	1531.7	1531.7	1531.7	1531.7	31543.3

ប្រភព៖ ការសិក្សាបច្ចុប្បន្នភាព សមិទ្ធិលទ្ធភាព ឆ្នាំ ២០១៧។

*បញ្ជាក់៖ ចំពោះផែនការផលិតអគ្គិសនី គឺមួយថ្ងៃ ១៣ ម៉ោង ទាំងរដូវប្រាំង និងវស្សា។ ការផលិតអគ្គិសនី អាស្រ័យលើការលើការចរចារ ទិញ-លក់អគ្គិសនីរវាង **EDC** និងម្ចាស់គម្រោង។ ដំណើការគម្រោង៣៥ឆ្នាំ*

៨.៦.១២ ផែនការគ្រប់គ្រងសំណល់គ្រប់ប្រភេទ (Waste Management Plan)

<u>ក. សំណល់រឹងចេញពីដំណើរការ សាងសង់អាង និងខ្សែបញ្ជូនចរន្តអគ្គិសនី</u>

សំណល់រឹងនេះ គឺមានសំណល់ ដី ថ្ម និង ឈើ:

- សំណល់ដី និងថ្ម ដែលយកពីការខួងជីករណ្តៅសម្រាប់សាងសង់បំពង់ទូនៃល គឺយកទៅចាក់ នៅទីតាំង ៣កន្លែង (ចំណុចនិយាមការមើល ចំណុច៤.៣ ខាងលើ) និងមួយចំណែកទៀត យកទៅចាក់បំពេញកន្លែងសាងសង់ការិយាល័យ ផ្ទះស្នាក់នៅរបស់បុគ្គលិកកម្មករគម្រោង ផ្លូវចេញចូលជាដើម។ ចំពោះជម្រាលជើងទេរ របស់កន្លែងចាក់ដីនិងថ្ម ត្រូវមាន 1:1.5 ជៀសវាងការហូរច្រោះដាច់ជញ្ជាំង។ ចំពោះសំណល់ ដីនិងថ្មនេះ មិនត្រូវចាក់ចូល តាមច្រាំងស្ទឹង អូរ ខាងក្រោមទំនប់មេ ដែលនាំ ឱ្យបំពុលទឹក និងលុបអន្លង់ តាមពោះស្ទឹង ដែលជាជម្រករបស់ពពួកមច្ឆជាតិ។
- ចំណែកឯ ឈើដែលនៅក្នុងអាង និងតាមគន្លងខ្សែបញ្ជូនអគ្គិសនី២៣0kV ម្ចាស់គម្រោងនិងធ្វើការសម្អាត ចេញមុនពេលបិទទឹកបំពេញអាង និងដំណើរការគម្រោង។ ចំពោះបែបបទ នៃការកាប់ឈើក្នុងអាង ម្ចាស់គម្រោង គោរពតាមបទបញ្ជារ ឬ ការណែនាំផ្សេងៗពីរាជរដ្ឋាភិបាល។
- ជាធម្មតាការសម្អាតឈើក្នុងអាងមានឈើមួយចំនួន មិនបានយកចេញ ពីព្រោះវានៅក្នុងទីចំណោទខ្លាំង ឬកន្លែងមិនអាចចូលបាន។ ហេតុដូចនេះ នៅពេលបំពេញទឹកអាងពេញដល់នីវ៉ូដំណើរការគម្រោង ម្ចាស់គម្រោង ត្រូវមានសាឡង់ ឬទូកសម្រាប់ ប្រមូលឈើអណ្តែតទឹកចេញទៀត ហើយចំពោះកន្លែងដែលមិនទាន់បានសម្អាត ពេលទឹកលិចចូលដល់អាចជិះកាណូតឬសាឡង់ចូលដល់ត្រូវកាប់សម្អាតចេញ ជៀសវាងការបំពុលខូចគុណភាពទឹកអាង។

ខ. សំណល់រឹង-រាវចេញពីការដ្ឋាន និងកន្លែងស្នាក់នៅរបស់បុគ្គលិកកម្មករគម្រោង

- ការបញ្ចោញសំណល់រឹងនេះ គឺនៅដំណាក់កាលសាងសង់គម្រោង ដែលបញ្ចោញដោយបុគ្គលិក-កម្មករ អ្នកម៉ៅការ និងបុគ្គលិក-កម្មករគម្រោងមានពីប្រភេទគឺសំណល់មិនគ្រោះថ្នាក់និងសំណល់គ្រោះថ្នាក់។ សំណល់មិនគ្រោះថ្នាក់ ធ្វើការប៉ាន់ប្រមាណពី១០០ទៅ១២០ គ.ក្រ/ថ្ងៃ មានដូចជា ក្រដាស់ ស្បោង ថង់ដបប្លាស្ទិក អំបែងដបកែវ និងសំណល់ផ្ទះបាយ ម្ចាស់គម្រោង និង អ្នកម៉ៅការ ត្រូវរៀបចំទុកដាក់ក្នុងរណ្តៅត្រឹមត្រូវ ដែលមានទីតាំងស្ថិតនៅឆ្ងាយ ពីប្រភពទឹក និងស្ថិតនៅក្រោមខ្សល់ មើលចំណុចនិយាមកាក្នុងចំណុច ៤.៣ ខាងលើ។ ចំណែកឯ សំណល់រឹងមិនគ្រោះថ្នាក់ដូចជា កេសឈើឬលោហៈ ដបឬកំប៉ុងប្លាស្ទិកឬលោហៈត្រូវយកប្រើប្រាស់ឡើងវិញឬលក់ឱ្យអេតចាយ។ ជាងនេះទៅទៀត ក្រុមហ៊ុនត្រូវមានបច្ចេកទេស ក្នុងការគ្រប់គ្រងសំណល់នៅទីតាំងចាក់សំរាមដោយមាន រថយន្ត សម្រាប់ចាក់ដី និងបង្ហាប់ពីលើសំណល់ជារៀងរាល់សប្តាហ៍ដើម្បីការពារ ក្លិន និងចាក់ដីជុំវិញ រណ្តៅ ដើម្បីការពារការហូរច្រោះទឹក ទៅបំពុលតំបន់ក្បែរៗនោះ ព្រមទាំង មានរបង ការពារសត្ត កុំឱ្យចូលក្នុងរណ្តៅទៀតផង។ ចំពោះសំណល់រឹងទាំងនេះ (សំរាមផ្ទះបាយ និងអាគារការិយាល័យ) ក្រុមហ៊ុននឹងមានអ្នកទទួលខុសត្រូវ ឬជួលឱ្យក្រុមហ៊ុនឯកជន ជាអ្នកគ្រប់គ្រង (មានលម្អិតបន្ថែម ឬអាចមានការផ្លាស់ប្តូរនៅពេលគម្រោងចាប់ផ្តើមការសាងសង់)។
- សំណល់គ្រោះថ្នាក់ ដូចជា សំណល់ខោអាវចាស់ៗ ដែលប្រឡាក់ប្រេង ឬស៊ីម៉ង់ត៍ កំប៉ុង ឬដបដាក់ប្រេង/ប្រេងរំអិល ថ្នាំលាប ឬសារធាតុ គីមីបាវ ស៊ីម៉ង់ត៍អំពូលភ្លើងខូច សំណល់ថ្មពិល អាគុយត្រូវចាក់ទឹកវាចេញទុកដោយឡែក ត្រូវដាក់ក្នុងធុងសំរាមមួយផ្សេង ដែលមានលាបព៌ណក្រហមសម្រាប់សម្គាល់ ហើយសរសេរជាអក្សរខ្មែរ និងអង់គ្លេស ដោយដាក់ថាធុងសំរាមសម្រាប់សំណល់រឹង-គ្រោះថ្នាក់ ដោយដាក់វាក្នុងថង់ប្លាស្ទិក(ក្រាស់) ដោយចងវាជិតល្អ។ សំណល់គ្រោះថ្នាក់នេះ ត្រូវសុំការប្រឹក្សា និងការរៀបចំទុកដាក់អគ្គនាយកដ្ឋានគាំពារបរិស្ថាន នៃក្រសួងបរិស្ថានផងដែរ។

Draft

- ដូចគ្នានិងសំណល់រឹងដែរ ចំពោះសំណល់រាវនៅដំណាក់កាលសាងសង់គម្រោង ដែលបញ្ចេញដោយបុគ្គលិក-កម្មករអ្នកម៉ៅការ និងបុគ្គលិក-កម្មករគម្រោង សំណល់នេះ មានដូចជា សំណល់រាវចេញពីបង្គន់ និងបន្ទប់ទឹក សារធាតុរាវ ដែលធ្វើឱ្យត្រជាក់ហួសកាលបរិច្ឆេទចេញពីគ្រឿងចក្រនានាគ្រប់ប្រភេទ សំណល់ទឹកលាយប្រេង សំណល់ប្រេងម៉ាស៊ីនចាស់ (ប្រេងបាត) សំណល់សូលុយស្យុងគីមីផ្សេងៗជាដើម។ល។ ចំពោះសំណល់រាវទាំងនេះ ត្រូវកំណត់ជាពីប្រភេទដែរគឺ សំណល់មិនគ្រោះថ្នាក់ដូចជាទឹកចេញពីបន្ទប់ទឹក សំណល់រាវចេញពីផ្ទះបាយ និងបង្គន់។ល។ ត្រូវធ្វើអាងសិបទិកទំនើបដែលមាន២ ឬ ៣ថតសម្រាប់ប្រព្រឹត្តកម្មវា។ ចំណែកឯ សំណល់រាវមានគ្រោះថ្នាក់ដូចជា ទឹកលាយប្រេងសារធាតុរាវ ដែលធ្វើឱ្យត្រជាក់ហួសកាលបរិច្ឆេទចេញពីគ្រឿងចក្រគ្រប់ប្រភេទ សំណល់សូលុយស្យុងគីមីផ្សេងៗ ជាដើមត្រូវគ្រប់គ្រងឱ្យបានល្អត្រឹមត្រូវដូចជា សំណល់ទឹកលាយប្រេងត្រូវធ្វើការញែកយកទឹកចេញ ហើយសល់ទឹកលាយប្រេង កំហាប់ខ្លាំង និងសំណល់រាវធ្វើឱ្យត្រជាក់សំណល់ប្រេងបាត និងសូលុយស្យុងផ្សេងៗ ត្រូវវេចខ្ចប់ ឱ្យបានល្អដោយត្រូវសុំការប្រឹក្សា និងរៀបរៀបចំទុកដាក់ពីអគ្គនាយកដ្ឋានគាំពារបរិស្ថាន នៃក្រសួងបរិស្ថាន។

<u>គ. សំណល់រឹង-រាវចេញពីកន្លែងលាយបេតុងរបស់គម្រោង</u>

សំណល់រឹង-រាវនេះ មានសំបកបាវស៊ីម៉ង់ត៍ សំណល់បេតុងលាយរួចមិនទាន់រឹង និងសំណល់រាវចេញពីការលាងសម្ភារលាយ និងដឹកជញ្ជូនបេតុង ត្រូវមានវិធានការដូចទៅ:

- បាវ ថង់ច្រកស៊ីម៉ង់ត៍ចាស់ដែលប្រើការមិនកើតត្រូវ ដឹកយកឱ្យរោងចក្រស៊ីម៉ង់ត៍កែច្នៃឡើងវិញ មិនបោះចោលពាសវាលពាសកាលនិងសុំការប្រឹក្សាយោបល់ពីអគ្គនាយកដ្ឋានគាំពារបរិស្ថាននៃក្រសួងបរិស្ថានក្នុងការរៀបចំទុកដាក់។
- សំណល់បេតុងដែលលាយរួច មានសល់នៅក្នុងរថយន្តដឹកបេតុង ត្រូវយកទៅចាក់នៅទីរាបឆ្ងាយពីប្រភពទឹក ឬចាក់ព្រឹងផ្លូវចេញចូល ហាមចាក់ពាសវាលពាសកាលក្បែរអូរ ឬស្ទឹង ដែលវានាំឱ្យបំពុលទឹកក្នុងតំបន់។ ម្យ៉ាងទៀត សំណល់ស៊ីម៉ង់ត៍ខូចគុណភាព (រឹង) ត្រូវរៀបចំទុកដាក់ ត្រឹមត្រូវ ដោយមានកន្លែងបាញ់ទឹក ធ្វើឱ្យស៊ីម៉ង់ត៍រឹងនេះស្រូបទឹកគ្រប់គ្រាន់មិនមានការហុយ និងបំពុលទឹកក្នុងតំបន់។
- នៅកន្លែងលាយបេតុង ត្រូវមានប្រព័ន្ធដោះទឹកត្រឹមត្រូវ ហើយនៅចុងប្រឡាយដោះទឹកនេះ ត្រូវសាងសង់រណ្តៅ ២ ដែលរណ្តៅនីមួយ២ មានទំហំ ១៥ម×១៥ម×ជម្រៅ២ម តជាប់គ្នា ដើម្បីកាត់បន្ថយភាពល្អក់ និងបន្ថយ pH នៅកន្លែងលាយបេតុងនោះ។

<u>ឃ. សំណល់ប្រកបដោយគ្រោះថ្នាក់</u>

ដូចបានរៀបរាប់ខាងលើរួចមកហើយ សំណល់នេះ គឺមាននៅតាមបណ្តាទីតាំងសាងសង់សំខាន់ៗរបស់គម្រោងមានដូចជា:

- សំណល់រឹង: សំណល់ខោអាវចាស់ៗ ដែលប្រឡាក់ប្រេងឬស៊ីម៉ង់ត៍ កំប៉ុង ឬដបដាក់ប្រេង/ប្រេងរំអិល ថ្នាំលាប ឬសារធាតុគីមី អំពូលភ្លើងខូច សំណល់ថ្មពិល អាគុយជាដើម។
- សំណល់រាវ: ទឹកលាយប្រេងសារធាតុរាវ ដែលធ្វើឱ្យត្រជាក់ហួសកាលបរិច្ឆេទចេញពីគ្រឿងចក្រគ្រប់ប្រភេទ សំណល់សូលុយស្យុងគីមីផ្សេងៗសម្រាប់

ចំពោះសំណល់គ្រោះថ្នាក់នេះ ត្រូវញែកចេញពីសំណល់ធម្មតា ហើយវេចខ្ចប់វាដាក់ក្នុងថង់ប្លាស្ទិករួច ដាក់ក្នុងធុងប្លាស្ទិកមានគម្របបិទជិតឱ្យបានត្រឹមត្រូវល្អ ទុកដាក់ក្នុងឃ្លាំងបណ្តោះអាសន្នដែលមានដំបូលជិតល្អ រួចត្រូវសុំការប្រឹក្សា និងការរៀបចំទុកដាក់ពីអគ្គនាយកដ្ឋានគាំពារបរិស្ថាន នៃក្រសួងបរិស្ថាន។

- ដូចគ្នានិងបង្គន់ដែរ សាងសង់បន្ទប់ទឹក ដាច់ដោយឡែកពីបុរស និងស្ត្រី។ ក្នុងបន្ទប់ទឹកទាំងនេះ ត្រូវមានអាងទឹក ឬធុងទឹក ឬទឹកផ្កាឈូក ដែលមានទឹកជាប្រចាំ ហើយមានដាក់លូឬអាងសិបទិកផងដែរ។ ចំនួនបន្ទប់ទឹក ដូចបង្គន់ផងដែរ យោងទៅតាមបរិមាណមនុស្ស។
- មានប្រព័ន្ធផ្គត់ផ្គង់ទឹក គ្រប់គាន់ដូចជា មានអាង ឬស៊ីនទែនទឹក ខ្ពស់សម្រាប់ចែកចាយទឹកជាដើម។
- មានអ្នកទទួលខុសត្រូវអ្នកបោសសម្អាតនិងប្រមូលសំរាមជាប្រចាំ(មើលផែនការគ្រប់គ្រងសំណល់រឹង-រាវខាងលើ)
- រៀបចំឱ្យមានកន្លែងអង្គុយសម្រាកគ្រប់គ្រាន់ និងមានកន្លែងចម្អិន និងបរិភោគអាហារ ដែលមានអនាម័យល្អ។
- ផ្តល់ទឹកបរិភាគ មានសុវត្ថិភាពគ្រប់គ្រាន់ដល់បុគ្គលិក-កម្មករគម្រោង


ផ្តល់ទឹកបរិភាគ មានសុវត្ថិភាព


មានកន្លែងបរិភោគអាហារ ដែលមានអនាម័យល្អ



សាងសង់បង្គន់និងបន្ទប់ទឹកដាច់ដោយឡែកពីបុរសនិងស្ត្រី

ខ. ផែនការរៀបចំស្នាក់នៅសម្រាប់បុគ្គិលិក-កម្ម ក្នុងដំណាក់កាលប្រតិបត្តិគម្រោង

ម្ចាស់គម្រោង នឹងត្រូវរៀបចំកន្លែងឬអាគារស្នាក់នៅ រួមទាំងផ្តល់ ជាសុខភាព និងអនាម័យដូចតទៅ៖

- ទីតាំងសាងសង់ត្រូវខ្ពស់ មិនមានទឹកលិច ឬដក់ទឹក នៅរដូវវស្សា មានប្រពន្ធ័ដោះទឹកត្រឹមត្រូវល្អ។
- មានសួនច្បារ និងទីធ្លាចតយានយន្ត ដែលមានដំបូល និងសុវត្ថិភាពល្អ។
- មានកន្លែងហាត់កីឡា អាងហែលទឹក កន្លែងកម្សាន្តផ្សេងៗ សម្រាប់បុគ្គលិក-កម្មករ។
- មានអាហារដ្ឋាន ឬកង់ទីន សម្រាប់បុគ្គលិក-កម្មករ ដែលមានអនាម័យល្អ។
- រាល់បន្ទប់ស្នាក់នៅសម្រាប់បុគ្គលិក-កម្មករ ត្រូវមាន ពន្លឺ ឬអំពូលភ្លើង គ្រាប់គ្រាន់ និងមានខ្យល់ចេញចូលល្អ បំពាក់ម៉ាស៊ីនត្រជាក់ ឬកង្ហារបត់ និងកង្ហារបឺតខ្យល់ចេញ។
- នៅតាមបន្ទប់ស្នាក់នៅមានបន្ទប់ទឹក និងបង្គន់អនាម័យល្អ រួមទាំងមានទឹកស្អាតតាមស្តង់ដារក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងមានបរិមាណគ្រប់គ្រាន់ផងដែរ។
- មានកន្លែងទុកដាក់សំរាម មានធុងសំរាម គ្រប់គ្រាន់។
- មានអ្នកមើលថែទាំទទួលខុសត្រូវ បោសសម្អាត ទីធ្លា និងសម្អាតធុងសំរាម ដោយយកទៅទុកដាក់តាមទីតាំងកំណត់ (មើលផែនការគ្រប់គ្រងសំណល់រឹងរាវខាងលើ)។
- មានអាងសិបទិក សម្រាប់ប្រព្រឹត្តកម្មសំណល់រាវចេញពីបន្ទប់ទឹក និងបង្គន់។
- នៅតាម អាគារ ទាំងអស់មានបំពាក់ អំពូលអគ្គិសនី ស្វ័យប្រវត្ត នៅពេលមានការដាច់អគ្គិសនី។
- នៅតាម អាគារ ទាំងអស់មានបំពាក់ ប្រដាប់ពន្លត់អគ្គីភ័យ (មើលប្រព័ន្ធការពារអគ្គិភ័យខាងលើ)។
- នៅទីតាំងអាគារស្នាក់នៅនីមួយៗតាមជាន់យ៉ាងហោចណាស់មានប្រអប់ថ្នាំពេទ្យសម្រាប់សង្គ្រោះបឋមផងដែរ


ប្រអប់ថ្នាំពេទ្យសម្រាប់សង្គ្រោះបឋម



បំពាក់ប្រដាប់ពន្លត់អគ្គីភ័យ

មានអ្នកមើលថែទាំទទួលខុសត្រូវថែទាំ និងអនាម័យ

Draft

៤.៦.១៤ តារាងពេលវេលានៃផែនការការសាងសង់ (General Construction Schedule)

ក្រុមហ៊ុនបានរៀបចំកាលវិភាគសម្រាប់សាងសង់គម្រោងដូចតទៅ: (សរុបរយៈពេលសាងសង់ ៤ឆ្នាំ) មើលតារាងលម្អិតក្នុងតារាង៤-៩ ខាងក្រោម:

សម្គាល់: *កាលបរិច្ឆេទសាងសង់គម្រោង មិនទាន់បានអនុម័ត ពីក្រសួងរ៉ែ និថាមពលនៅឡើយ ដូចនេះ នៅពេលដែលក្រសួងនេះ ចុះកិច្ចសន្យា វិនិយោគឱ្យក្រុមហ៊ុន KTC ឬមួយយ៉ាណា និងបញ្ជាក់នៅពេលក្រោយ។ រយៈពេលសាងសង់មាន៥ឆ្នាំ ប្រសិនកំណត់ថ្ងៃ ឬខែនៃការសាងសង់គម្រោងនោះ នឹងដឹងច្បាស់នៃការបញ្ចប់ការសាងសង់គម្រោង។*

តារាង ៤- ៩: សង្ខេបកាលវិភាគសម្រាប់សាងសង់គម្រោង

ល.រ	បរិយាយ	រយៈពេល (ខែ)	ពេលរៀបចំមុនការសាងសង់	ឆ្នាំទី១												ឆ្នាំទី២												ឆ្នាំទី៣												ឆ្នាំទី៤											
				1	2	3	4	5	6	7	8	9	10	11	12	1	2	3	4	5	6	7	8	9	10	11	12	1	2	3	4	5	6	7	8	9	10	11	12	1	2	3	4	5	6	7	8	9	10	11	12
1	ការរៀបចំមុនពេលសាងសង់គម្រោង (ផ្លូវចេញចូលប្រព័ន្ធទឹក អគ្គិសនី, ជំរុំស្នាក់នៅ កន្លែងលាយបេតុង....)	9																																																	
2	ការសាងសង់សំណង់បណ្តោះអាសន្ន(ទំនប់បណ្តោះអាត្ត១ អេលពង្វាងទឹក	11																																																	
3	ការសាងសង់បេដ្យោចនាសម្ព័ន្ធវារីអគ្គិសនី (ទំនប់បេ ទំនប់ បង្ហៀរ ក្នុងមូរអេលវ៉ាទឹក អាគារថាមពល.....	34																																																	
4	បញ្ចប់ការសាងសង់ និងការសាងល្បង	3																																																	
	សរុបរយៈពេលសាងសង់	48																																																	

<u>សម្គាល់:</u>

សកម្មភាពការងារពេញម៉ោង

សកម្មភាពការងារជាដំណាក់ៗ

បញ្ជាក់: *រយៈពេលសរុបនៃការសាងសង់គម្រោង ៤៨ ខែ គឺស្មើនិង ៤ឆ្នាំ រយៈពេលនេះមិនទាន់បានគិតបញ្ចូលរយៈពេលរៀបចំមុនការសាងសង់ ៩ ខែនោះទេ។*

Draft